ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**តុលាការកំពូល**

**សភាព្រហ្មទណ្ឌ**

សំណុំរឿងព្រហ្មទណ្ឌ

លេខ ៤៦

ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០២២

សាលដីកា

លេខ ៣២៧ "II"

ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២២

# សាលដីកា

## តាងនាមប្រជារាស្ត្រខ្មែរ

## តុលាការកំពូល

**បានបើកសវនាការជាសាធារណៈនៅថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០២២**

**ដោយអង្គជំនុំជម្រះមានសមាសភាពដូចខាងក្រោម ៖**

១. ឯកឧត្តម [redacted] ជាប្រធាន

២. ឯកឧត្តម [redacted] ជាចៅក្រម

៣. ឯកឧត្តម [redacted] ជាចៅក្រម

៤. ឯកឧត្តម [redacted] ជាចៅក្រម

៥. លោកជំទាវ [redacted] ជាចៅក្រម

**ចៅក្រមរបាយការណ៍**

ឯកឧត្តម [redacted]

**ក្រឡាបញ្ជីសវនាការ**

លោក [redacted]

**តំណាងមហាអយ្យការ**

ឯកឧត្តម [redacted] ឋានៈជាព្រះរាជអាជ្ញា

**ដើម្បីជំនុំជម្រះ**

លើបណ្ដឹងសាទុក្ខលេខ ៤៣៣ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២១ របស់ជនជាប់ចោទឈ្មោះ [redacted] វាសនា ហៅ ស្នា ប្ដឹងចំពោះសាលដីកាព្រហ្មទណ្ឌលេខ ១១៨ ក្រVទ ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០២១ របស់សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ភ្នំពេញ ដែលមាន ៖

**-បុគ្គលប្ដឹងសាទុក្ខ** ៖ ជនជាប់ចោទឈ្មោះ [redacted] វាសនា ហៅ ស្នា ភេទប្រុស អាយុ ២២ឆ្នាំ ជនជាតិខ្មែរ មុខរបរបើកឡានពេទ្យ មានទីកន្លែងកំណើតនៅភូមិទួលតាឯក ឃុំទួលតាឯក ស្រុកស្វាយប៉ោ ខេត្តបាត់ដំបង និងមានលំ[redacted] ភូមិទួលតាឯក សង្កាត់ទួលតាឯក



Scanned with CamScanner

ក្រុងបាត់ដំបង ខេត្តបាត់ដំបង។ ឪពុកឈ្មោះ [redacted] "ស" ម្តាយឈ្មោះ [redacted] "រ" នៅលីវ ទោសពីមុនគ្មាន។ (ក្រៅឃុំ)

-**ជាប់ចោទពីបទ ៖** រំលោភសេពសន្ថវៈ ប្រព្រឹត្តនៅចំណុចផ្ទះសំ[redacted] សង្កាត់ទួលតាឯក ក្រុងបាត់ដំបង ខេត្តបាត់ដំបង កាលពីថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៦ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៣៩ នៃក្រមព្រហ្មទណ្ឌ។

-មានលោក [redacted]វង្ស ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ។

-**ដើមបណ្តឹងរដ្ឋប្បវេណីនិងជាជនរងគ្រោះ ៖** ឈ្មោះ [redacted] ចិន្តា ភេទស្រី អាយុ ២៥ឆ្នាំ ជនជាតិខ្មែរ មានលំនៅឋានបច្ចុប្បន្ន[redacted] សង្កាត់រតនៈ ក្រុងបាត់ដំបង ខេត្តបាត់ដំបង។

## អំពីអង្គហេតុ

កាលពីថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៦ ឈ្មោះ [redacted] ចិន្តា ភេទស្រី បានធ្វើដំណើរពីភ្នំពេញមកបាត់ដំបងវេលាម៉ោងមួយរំលងអាធ្រាត ហើយក៏បានពឹងឈ្មោះ [redacted] វាសនា ភេទប្រុស អាយុ ២៥ឆ្នាំ ឱ្យជូនទៅផ្ទះ ប៉ុន្តែឈ្មោះ [redacted] វាសនា បដិសេធថាមិនជូនទៅផ្ទះទេព្រោះយប់ជ្រៅហើយ ក៏បានល្បួងជនរងគ្រោះឈ្មោះ [redacted] ចិន្តា ឱ្យទៅសម្រាកនៅផ្ទះ[redacted] សង្កាត់ទួលតាឯក ក្រុងបាត់ដំបង ខេត្តបាត់ដំបង មួយយប់សិន ចាំព្រឹកឡើងជូនទៅផ្ទះ។ លុះពេលទៅដល់ក្នុងបន្ទប់ផ្ទះសំណាក់ឈ្មោះ [redacted] វាសនា បានចាក់សោ និងចាក់គន្លឹះទ្វារជាប់ ហើយក៏ច្រានជនរងគ្រោះឱ្យដួលទៅលើគ្រែ រួចបានខ្ទប់មាត់ជនរងគ្រោះមិនឱ្យស្រែក ហើយក៏បានចាប់រំលោភជនរងគ្រោះរហូតដល់បានសម្រេចតែម្តង ខណៈពេលធ្វើសកម្មភាពឈ្មោះ [redacted] វាសនា ភេទប្រុស បានគំរាមជនរងគ្រោះមិនឱ្យស្រែក បើហ៊ានស្រែកនឹងច្របាច់កសម្លាប់ចោលភ្លាម។

-បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ "៤៦១ ឃ" ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១៨ របស់សាលាដំបូងខេត្តបាត់ដំបងដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ ៖

១-ផ្តន្ទាទោសឈ្មោះ [redacted] វាសនា ភេទប្រុស អាយុ ២២ឆ្នាំ ជាតិខ្មែរ (សាវតារជាតិគ្រប់គ្រាន់ខាងលើ) ដាក់ពន្ធនាគារកំណត់ ៥ (ប្រាំ)ឆ្នាំ ពីបទ រំលោភសេពសន្ថវៈ តាមមាត្រា ២៣៩ នៃក្រមព្រហ្មទណ្ឌ ប្រព្រឹត្តនៅចំណុចផ្ទះ[redacted] សង្កាត់ទួលតាឯក ក្រុងបាត់ដំបង ខេត្តបាត់ដំបង កាលពីថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៦។

២-ឱ្យឈ្មោះ [redacted] វាសនា សងសំណងជំងឺចិត្តជាប្រាក់ចំនួន ៨.០០០.០០០(ប្រាំបីលាន)រៀល ឱ្យទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ចិន្តា។ ការទាមទារលើសពីនេះត្រូវច្រានចោល។



Scanned with CamScanner

សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៨ និងប្រកាសជាសាធារណៈនៅថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១៨ ចំពោះមុខជនជាប់ចោទនិងដើមបណ្តឹងរដ្ឋប្បវេណី។

ទុកសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

-បានឃើញ បណ្តឹងឧទ្ធរណ៍លេខ ៤៨ ចុះថ្ងៃទី០៩ ខែសីហា ឆ្នាំ២០១៩ របស់លោក [redacted] តារា ជាមេធាវីទទួលសិទ្ធិក្នុងការប្តឹងឧទ្ធរណ៍ឱ្យជនជាប់ចោទឈ្មោះ [redacted] វាសនា ដែលប្តឹងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ "៤៦១ ឃ" ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៨ របស់សាលាដំបូងខេត្តបាត់ដំបង ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងស្រុងក្នុងសាលក្រម។

-បានឃើញ សាលដីកាព្រហ្មទណ្ឌលេខ ១១៨ ក្រVរន ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០២១ របស់សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ៖

១. ទទួលពាក្យបណ្តឹងឧទ្ធរណ៍លេខ ៤៨ ចុះថ្ងៃទី០៩ ខែសីហា ឆ្នាំ២០១៨ របស់លោកមេធាវី [redacted] តារា ការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] វាសនា ហៅ ស្នា ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់។

២. តម្កល់សាលក្រមព្រហ្មទណ្ឌលេខ "៤៦១ ឃ" ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១៨ របស់សាលាដំបូងខេត្តបាត់ដំបង ទុកជាបានការដដែល។

សាលដីកានេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០២១ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] វាសនា កំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ចិន្តា និងប្រកាសជាសាធារណៈនៅថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០២១។

ទុកសិទ្ធិប្តឹងទាស់ ប្តឹងសាទុក្ខតាមកំណត់ច្បាប់។

-បានឃើញ បណ្តឹងសាទុក្ខលេខ ៤៣៣ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២១ របស់ជនជាប់ចោទឈ្មោះ [redacted] វាសនា ហៅ ស្នា ដែលប្តឹងមិនសុខចិត្តនឹងសាលដីកាព្រហ្មទណ្ឌលេខ ១១៨ ក្រVរន ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០២១ របស់សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ភ្នំពេញ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល។

## នាពេលសវនាការតុលាការកំពូល

-ចៅក្រមរបាយការណ៍បានធ្វើសេចក្តីរាយការណ៍។

-តំណាងមហាអយ្យការអមតុលាការកំពូលបានធ្វើសេចក្តីសន្និដ្ឋាន ជនជាប់ចោទដែលជាម្ចាស់បណ្តឹងសាទុក្ខបានទទួលលិខិតជូនដំណឹងឱ្យដាក់សារណាការពារនៅថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២១ រួចហើយ



Scanned with CamScanner

ប៉ុន្តែជនជាប់ចោទមិនបានដាក់សារណាការពារជូនតុលាការកំពូលទេ។ ដូចនេះយោងតាមមាត្រា ៤៣១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ តុលាការកំពូលជំនុំជម្រះ ពិនិត្យ ពិចារណា តែទៅលើមូលហេតុនៃបណ្តឹងសាទុក្ខតែប៉ុណ្ណោះ ប៉ុន្តែជនជាប់ចោទមិនបានដាក់សារណាបញ្ជាក់អំពីមូលហេតុនៃបណ្តឹងសាទុក្ខរបស់ខ្លួនជូនតុលាការកំពូលទេ។ ហេតុដូច្នេះតំណាងមហាអយ្យការអមតុលាការកំពូលស្នើសុំក្រុមប្រឹក្សាជំនុំជម្រះមេត្តាពិនិត្យនិងសម្រេចតាមច្បាប់។

-លោកមេធាវី [redacted]វង្ស ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] វាសនា ហៅ ស្នា បានធ្វើសេចក្តីសន្និដ្ឋានថា ក្នុងរឿងក្តីនេះបើយោងតាមទីតាំងកន្លែងកើតហេតុ ស្ថានភាពនៃជនរងគ្រោះ រយៈពេលនៃការប្តឹង ចម្លើយបំភ្លឺរបស់ជនជាប់ចោទ អះអាងពីភាពស្មោះត្រង់របស់គាត់ និងចម្លើយបំភ្លឺបញ្ជាក់ការពិតរបស់ជនរងគ្រោះ គឺរកមិនឃើញចំណុចណាមួយដែលបង្ហាញថាជាអំពើចាប់រំលោភនោះទេ។ វាគឺជាការព្រមព្រៀងគ្នារវាងជនជាប់ចោទនិងជនរងគ្រោះ ដែលគាត់ទាំងពីរនាក់ជាសង្សានឹងគ្នា។ ហេតុដូច្នេះផ្អែកតាមមាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញ និងមាត្រា ៣៥១ នៃក្រមព្រហ្មទណ្ឌចែងថា *"វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទជានិច្ច"* ។ ហេតុដូច្នេះក្នុងនាមខ្លួនជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] វាសនា សុំសំណូមពរដល់ឯកឧត្តមប្រធាន ក៏ដូចជាឯកឧត្តម លោកជំទាវជាចៅក្រមប្រឹក្សា មេត្តាសម្រេចឱ្យកូនក្តីខ្លួនរួចផុតពីបទចោទ។

-ក្រោយពីបានស្តាប់សេចក្តីរាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមតុលាការកំពូល

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

-ក្រោយពីបានពិនិត្យ ពិចារណា ពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## សំអាងហេតុ
## តុលាការកំពូល

១-យល់ឃើញថា បណ្តឹងសាទុក្ខលេខ ៤៣៣ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២១ របស់ជនជាប់ចោទឈ្មោះ [redacted]វាសនា ហៅ ស្នា ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងក្តីនេះមកជំនុំជម្រះបាន តាមបទប្បញ្ញត្តិមាត្រា ៦៤ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ និងមាត្រា ៤១៧, មាត្រា ៤១៨ និងមាត្រា ៤២០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២-យល់ឃើញថា ជនជាប់ចោទនិងដើមបណ្តឹងរដ្ឋប្បវេណីអវត្តមាន ដោយមិនចូលរួមក្នុងសវនាការពិភាក្សាដេញដោល តាមដីកាកោះ និងលិខិតអញ្ជើញរបស់តុលាការកំពូលទេ ប៉ុន្តែបានទទួលដំណឹងអំពី



Scanned with CamScanner

កាលបរិច្ឆេទនេះរួចហើយ។ តែមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទបានចូលរួមសវនាការហើយ ដូច្នេះ តុលាការកំពូលអាចបន្តនីតិវិធីសវនាការបាន។

៣-យល់ឃើញថា ការដែលសាលាដំបូងខេត្តបាត់ដំបង និងសាលាឧទ្ធរណ៍ភ្នំពេញបានសម្រេចប្រកាសពិរុទ្ធភាពនិងផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ [redacted] វាសនា ហៅ ស្នា ពីបទរំលោភសេពសន្ថវៈប្រព្រឹត្តនៅចំណុចផ្ទះសំ[redacted]នៅភូមិអូរតាគាំ១ សង្កាត់ទួលតាឯក ក្រុងបាត់ដំបង ខេត្តបាត់ដំបង កាលពីថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៦ បទល្មើសព្រហ្មទណ្ឌដែលមានបញ្ញត្តនិងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៣៩ នៃក្រមព្រហ្មទណ្ឌ ដោយសំអាងជាចម្បងលើចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលបានឆ្លើយថា នៅថ្ងៃកើតហេតុ ពេលចូលទៅដល់បន្ទប់ផ្ទះសំណាក់ ឈ្មោះ [redacted] វាសនា បានចាក់សោ ដាក់គន្លឹះទ្វារបន្ទប់ រួចចាប់ខ្លួនខ្ទប់មាត់ និងចាប់បោកខ្លួនទៅលើគ្រែ ព្រមទាំងចាប់រំលោភរហូតបានសម្រេច ហើយបានគំរាមខ្លួនមិនឱ្យស្រែក បើហ៊ានស្រែកឱ្យឮគេដឹងនឹងច្របាច់កខ្លួនសម្លាប់ចោល ទើបខ្លួនមិនហ៊ានស្រែក នោះជាការមិនត្រឹមត្រូវទេ ពីព្រោះថា ៖

ក.អង្គហេតុថាមានអំពើរំលោភសេពសន្ថវៈ ដែលបានលើកឡើងដោយដើមបណ្តឹងរដ្ឋប្បវេណីនេះ ពុំមានបញ្ជាក់ដោយភស្តុតាងផ្សេងទៀតដូចជា ជាសាក្សី ស្លាកស្នាមនៅកន្លែងកើតហេតុ ស្លាកស្នាមនៅលើខ្លួនជនរងគ្រោះ ឬជាឯកសារលទ្ធផលកោសល្យវិច័យប្រដាប់ភេទរបស់ជនរងគ្រោះដែលចេញដោយគ្រូពេទ្យជំនាញឯកទេសនោះទេ ។

ខ.តាមចម្លើយរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណីនិងជាជនរងគ្រោះ[redacted] ចិន្តា នៅគ្រប់ដំណាក់កាលនៃកិច្ចស៊ើបសួរបានទទួលស្គាល់រយៈពេលជាងមួយឆ្នាំកន្លងមកហើយ និងថា នៅមុនពេលកើតហេតុ ខ្លួននិងឈ្មោះ [redacted] វាសនា ត្រូវជាមិត្តភក្តិនឹងគ្នា។ នៅថ្ងៃកើតហេតុខ្លួន បានទំនាក់ទំនងជាមួយឈ្មោះ [redacted] វាសនា តាមទូរស័ព្ទ ហើយឈ្មោះ [redacted] វាសនា បានទៅទទួលខ្លួននៅបេនឡាន ព្រមទាំងបានឯកភាពគ្នាទៅដេកនៅផ្ទះសំណាក់បុរីថ្មី។ លុះព្រឹកឡើងឈ្មោះ [redacted] វាសនា បានជូនខ្លួនទៅផ្ទះ បន្ទាប់មកក៏បាននាំម្តាយនិងចាស់ទុំទៅចូលស្តីដណ្តឹងខ្លួន ប៉ុន្តែរយៈពេលមួយឆ្នាំក្រោយក៏បានសុំផ្តាច់ពាក្យវិញ ទើបខ្លួនប្តឹងទៅអយ្យការអមសាលាដំបូងខេត្តបាត់ដំបង ចោទប្រកាន់លើឈ្មោះ [redacted] វាសនា ពីបទរំលោភសេពសន្ថវៈនៅបន្ទប់ផ្ទះសំណាក់បុរីថ្មី កាលពីយប់ថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៦ តាមពាក្យបណ្តឹងចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១៧ អង្គហេតុនេះបានបង្ហាញពីភាពត្រូវរ៉ូវគ្នារវាងឈ្មោះ [redacted] វាសនា ជាមួយនឹងឈ្មោះ [redacted] ចិន្តា ភាគីដើមបណ្តឹងរដ្ឋប្បវេណីក្នុងការរួមភេទ។

តុលាការកំពូលអាចសន្និដ្ឋានបានថា ពុំមានធាតុផ្សំជាបទល្មើស និងគ្មានពិរុទ្ធភាពលើជនជាប់ចោទ ឈ្មោះ [redacted] វាសនា ហៅ ស្នា ពីបទរំលោភសេពសន្ថវៈ ប្រព្រឹត្តនៅចំណុចផ្ទះសំណាក់បុរីថ្មី ស្ថិតនៅ



Scanned with CamScanner

ភូមិអូរតាគាំ១ សង្កាត់ទួលតាឯក ក្រុងបាត់ដំបង ខេត្តបាត់ដំបង កាលពីយប់ថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៦ បទល្មើសព្រហ្មទណ្ឌដែលមានបញ្ញត្តនិងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៣៩ នៃក្រមព្រហ្មទណ្ឌឡើយ។

ដូច្នេះ បណ្តឹងសាទុក្ខរបស់ជនជាប់ចោទឈ្មោះ [redacted] វាសនា ហៅ ស្នា មានមូលហេតុនៃបណ្តឹងសាទុក្ខសមស្របតាមបញ្ញត្តិមាត្រា ៤១៩ ត្រង់ចំណុចទី៤ ការបំពានច្បាប់ ឬការអនុវត្តខុសច្បាប់ និង ត្រង់ចំណុចទី៧ ការបំភ្លៃងអង្គហេតុ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

៤.យល់ឃើញថា តាមសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការនិងសេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទបានលើកឡើងនាពេលសវនាការ ពិភាក្សាដេញដោលរបស់តុលាការកំពូលមានខ្លឹមសារប្រហាក់ប្រហែលនឹងផ្នែកសំអាងហេតុ ត្រង់ចំណុចទី៣ របស់តុលាការកំពូលដែរ និងប្តឹងសុំឱ្យតុលាការកំពូលសម្រេចតាមច្បាប់ នោះគឺជាសេចក្តីសន្និដ្ឋានមានមូលដ្ឋានសំអាងលើអង្គហេតុ ភស្តុតាង និងអង្គច្បាប់ត្រឹមត្រូវសមស្របហើយ។

៥-យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ ១៨៨ ក្រVរន ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០២១ របស់សភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍ភ្នំពេញបានសម្រេចមកនេះមិនត្រឹមត្រូវនឹងគតិច្បាប់ទេ។

## ហេតុដូច្នេះ

## សម្រេចសេចក្តី

១-ទទួលបណ្តឹងសាទុក្ខលេខ ៤៣៣ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២១ របស់ជនជាប់ចោទឈ្មោះ [redacted] វាសនា ហៅ ស្នា។

២-បដិសេធសាលដីកាព្រហ្មទណ្ឌលេខ ១១៨ ក្រVរន ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០២១ របស់សាលាឧទ្ធរណ៍ភ្នំពេញ។

៣-ឱ្យឈ្មោះ [redacted] វាសនា ហៅ ស្នា ភេទប្រុស កើតថ្ងៃទី១៣ ខែតុលា ឆ្នាំ១៩៩៥ សញ្ជាតិខ្មែរ មុខរបរបើកបររថយន្ត មានទីកន្លែងកំណើតនៅភូមិទួលតាឯក ឃុំទួលតាឯក ស្រុកស្វាយប៉ោ ខេត្តបាត់ដំបង មានលំនៅឋាន[redacted] ក្រុមទី២៣ ភូមិទួលតាឯក សង្កាត់ទួលតាឯក ក្រុងបាត់ដំបង ខេត្តបាត់ដំបង ឪពុកឈ្មោះ [redacted] "ស" ម្តាយ ឈ្មោះ [redacted] "រ" នៅលីវ ទោសពីមុនគ្មាន (ក្រៅឃុំ) រួចខ្លួនពីបទចោទប្រកាន់ បទរំលោភសេពសន្ថវៈ ប្រព្រឹត្តនៅចំណុ[redacted] ស្ថិតនៅភូមិអូរតាគាំ១ សង្កាត់ទួលតាឯក ក្រុងបាត់ដំបង ខេត្តបាត់ដំបង កាលពីថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៦ បទល្មើសព្រហ្មទណ្ឌ ដែលមានបញ្ញត្តនិងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៣៩ នៃក្រមព្រហ្មទណ្ឌ និង ឱ្យរួចផុតពីការសងសំណងជំងឺចិត្តចំនួន ៨.០០០.០០០ រៀល ទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted]។



Scanned with CamScanner

សាលដីកានេះបានជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០២២ និងប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២២។

**សមាសភាពនៃអង្គជំនុំជម្រះ**

ឯកឧត្តម [redacted] ជាប្រធាន

ឯកឧត្តម [redacted] ជាចៅក្រម

ឯកឧត្តម [redacted] ជាចៅក្រម

ឯកឧត្តម [redacted] ជាចៅក្រម

លោកជំទាវ [redacted] ជាចៅក្រម

លោក [redacted] ជាក្រឡាបញ្ជី

---

**បានចម្លងត្រឹមត្រូវតាមច្បាប់ដើម។**

ថ្ងៃសុក្រ ២រោច ខែអាសាឍ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

រាជធានីភ្នំពេញ, ត្រូវនឹងថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២២

**ក្រឡាបញ្ជី**

[redacted]

**បានឃើញ**

ថ្ងៃសុក្រ ២រោច ខែអាសាឍ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

រាជធានីភ្នំពេញ, ត្រូវនឹងថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២២

**ប្រធានអង្គជំនុំជម្រះ**

[redacted]

.......................................................................................................................................

“យើង [redacted] ក្រឡាបញ្ជីតុលាការកំពូល បញ្ជាក់ថា សាលដីកានេះ បានចូលជាស្ថាពរ នៅថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២២ និងមានអានុភាពអនុវត្តតាមច្បាប់។”

“សេចក្តីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជាទ្រង់ត្រាស់បង្គាប់មកអ្នកអនុវត្តសាលដីកាឱ្យសម្រេចតាមសាលដីកានេះ និងឱ្យអាជ្ញាធរគ្រប់តំណែង គ្រប់ថ្នាក់ជួយអនុវត្តសាលដីកានេះ បើមានសំណូមពរត្រឹមត្រូវតាមច្បាប់។”

ថ្ងៃថ្ងៃសុក្រ ២រោច ខែអាសាឍ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

រាជធានីភ្នំពេញ, ត្រូវនឹងថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២២

**ក្រឡាបញ្ជី**

[redacted]



Scanned with CamScanner